<u>លិខិតសំណូមពរ</u>

ខ្ញុំបាទជាប្រជាមួយរូប តំណាងអោយប្រជាជនទូទាំងឃុំប្រាំយ៉ាម ក្នុងស្រុកស្រីសន្ធរខេត្តកំពង់ចាម។ ត្រូវរងគ្រោះដោយក្រុមចោរប្លន់ជាច្រើន ធ្វើអោយភ័យខ្លាចរាល់ពេលវេលា គ្មានសេរីភាពរស់នៅ រងចាំតែថ្ងៃស្លាប់ រីក៏ទទួលទារុណកម្ម ដោយក្រុមចោរប្លន់ វាយបង្គាប់អោយរកមាសជាច្រើនតំឡឹងមកជូនបងមេចោរប្លន់ ហើយប្រសិនជាមិនបានពួកចោលបង្ខំចិត្តអោយចេញទៅក្រៅភូមិ ដើម្បីបាញ់ប្រហារជីវិត។ ជាមួយគ្នានេះដែលប្រជាជនខ្លះពុំមានមាសឲ្យ ត្រូវពួកបងៗក្រុមចោរ គំរាមសំឡុតដោយដោះសំពត់ ខោ អាវចេញពីខ្លួនដើម្បីឆែករកមាសចំពោះស្រីៗ។ រីប្រុសៗត្រូវគេចងសេកយ៉ាងណែន ភ័យរន្ធត់ព្រលឹងចុងសក់។ តើទុក្ខវេទនារបស់ប្រជាជន នៅមានប៉ុន្មានយ៉ាងទៀត។ បើតាំងតែពីខ្ញុំបានឃើញពន្លឺព្រះអាទិត្យមក ស្គាល់តែព្រាត់ប្រាស និងអត់ឃ្លាន ដោយសត្រូវ ឈ្លានពាន ទំលាក់គ្រាប់បែក។ ប៉ុលពត ប្រល័យពូជសាសន៍ ហើយសល់ពីស្លាប់ត្រូវរស់នៅក្នុងសភាពក្រតោកយ៉ាក បានព្រឹកខ្វះល្ងាច បានល្ងាចខ្វះព្រឹក។ ទោះបីជារស់នៅក្នុងរបបគ្រប់គ្រងរបស់រដ្ឋកម្ពុជាក៏ប្រជាជនឃុំនេះ ពុំបានធូរស្រាលឡើយ ដោយសារការធ្វើដំណាំស្រូវឆ្នាំខ្លះរលួយដោយសារទឹកទន្លេលិច ឆ្នាំខ្លះស្អកដោយមូលហេតុពុំសូវសំបូរទឹកភ្លៀង។ ហេតុដូចបានជំរាបបានធ្វើអោយប្រជាជនស្រីៗមួយចំនួនបង្ខំចិត្តចេញពីភូមិកំណើតរបស់ខ្លួន ទៅស៊ីឈ្នួលគេនៅស្រុកក្រៅ។ ចំណែកប្រុសៗត្រូវសំរេចចិត្ត ទៅលីដែកអោយថៅកែភ្នំពេញ។ ខ្ញុំសួរទៅបងចោរប្លន់ថា បើក្រលំបាកវេទនាយ៉ាងនេះមានមាសប្រាក់ឯណាសំរាប់ទុកអោយប្លន់នោះ។ ចំណែកខ្ញុំជាប្រជាជនដែលត្រូវរងគ្រោះដែលនោះ អាចវាស់បានថា មានមែនមាស ប្រហែល ៤ជីទៅ ៦ជី ចំពោះប្រជាអ្នកមាន ឃុំប្រាំយ៉ាម។ បើមានតិចតួច ស្ដួចស្ដើងយ៉ាងនេះ ហេតុអ្វីក៏បងចោរប្លន់មកយកបង្ហើយល្អម្ល៉េះ។ ជាទីបញ្ចប់នេះ ខ្ញុំបាទសូមបួងសួងទៅដល់ម្ចាស់វាសនានិង ម្ចាស់ជីវិតរបស់ប្រជាជន មាន( សម្ដេចនិងលោកដែលជាប្រថានរដ្ឋាភិបាលថ្មី) មកជួយការពារឃុំនេះអោយស្រួលឡើង ព្រោះប្រជាជននៅអស់សង្ឃឹម [UW] មិនចង់រស់នៅ ដោយគិតថាខំរកបានទាំងលំបាក បានបន្តិចបន្តួចគេមកគំរាមយក ដូចជារបស់គេទុកពីថ្ងៃណា តើមានប្រយោជន៍អ្វី បើរស់នៅស្គាល់តែវេទនា។ ដូច្នេះមានតែតដៃ តែបើតខ្លាចស្លាប់ព្រោះចោរមានកាំភ្លើង។ ដូចនេះសរុបមកគ្មានអ្វីជាទីសង្ឃឹមទេ មានតែលិខិតសំណូមពរនេះទេ ដែលអាចយកព័ត៌មានទៅប្រាប់ចោរប្លន់និងរដ្ឋាភិបាលថ្មី។ ខ្ញុំបាទទុកចិត្តនិងសង្ឃឹមយ៉ាងខ្លាំងថាប្រាកដជាវិទ្យុ អ៊ុន តាក់ ចាប់អារម្មណ៍ចាក់ផ្សាយរាល់ពេលផ្សាយជាពុំខាន។ សូមជូនពរសម្ដេចឪ អ៊ុនតាក់ និរដ្ឋាភិបាលថ្មី បានសុខសប្បាយ គ្រប់ទិវារាត្រី គួរពុំគួរ អនុគ្រោះផង អរគុណ។

ផ្ញើថ្ងៃទី ៧. ៨.៩៣